## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

## ការចាប់ផ្តើមវគ្គសិក្សាភាសាជប៉ុនដោយមិនគិតថ្លៃតាមអនឡាញ "Minato"

២៧ កុម្ភៈ ឆ្នាំ ២០១៧

វិទ្យាស្ថានភាសាជប៉ុននៃមូលនិធិជប៉ុន បានចាប់ផ្តើមវគ្គសិក្សាភាសាជប៉ុនតាមអនឡាញដោយឥតគិតថ្លៃ ដែលមានឈ្មោះថា "JF Japanese e-Learning Minato" សម្រាប់អ្នករៀនភាសាជប៉ុនទូទាំងពិភពលោក។

"Minato" គឺជាកម្មវិធីថ្មីសម្រាប់ទំនាក់ទំនងស្វែងយល់អំពីការសិក្សាភាសាជប៉ុនយ៉ាងទូលំទូលាយ។ កម្មវិធីនេះ បានផ្តល់នូវកំរិតសិក្សាទៅតាមសៀវភៅមួយចំនួនដូចជា សៀវភៅ" Marugoto" ដែលមានបង្រៀនភាសា និង វប្បធម៌ជប៉ុន សៀវភៅ "Japanese in Anime & Manga " គឺជាសៀវភៅដើម្បីរៀនឲ្យនិយាយដូចជាតួអង្គតុក្កតាជប៉ុន និង "Writing" គឺយកតាមប្រព័ន្ធការសរសេរភាសាជប៉ុន។

ក្រៅពីនេះមាន "វគ្គស្វ័យសិក្សា" ហើយ សិស្សអាចរៀនជាមួយគ្រូ និង មិត្តរួមថ្នាក់នៅក្នុង"វគ្គបំប៉នបន្ថែម"។

"Minato " ក៏ផ្តល់នូវវេទិកាមួយដែលអ្នកអាចផ្សាភ្ជាប់បានជាមួយអ្នកចូលរួមពីទូទាំងសកលលោក។

យើងសង្ឃឹមថា ប្រជាជនកម្ពុជាជាច្រើននឹងរីករាយរៀនភាសាជប៉ុន និងជួបប្រាស្រ័យទាក់ទងជាមួយប្រជាជនទូទាំងសកលលោក តាមរយៈ" Minato"។

គេហទំព័រ JF Japanese e-Learning Minato : https://minato-jf.jp

Embassy of Japan, No. 194 Preah Norodom Blvd, Tel: (023) 217-161/4, Fax: (023) 216 162, Email: info.jpn@pp.mofa.go.jp,
Official Website: www.kh.emb-japan.go.jp